# បណ្ដឹងឧទ្ធរណ៍


## ឧទ្ទេសនាមដោយ៖ លោកមេធាវី អ៊ីវ ប៉ូលី

### ជំនួយការរៀបចំ៖

### ឆន ឆៃយ៉ារត្តី ឈុំ មុនីសុជាតា

### ពេជ្រ ចាន់មុនី ចំរើន ប៊ុនរ៉ុង


02/12/2018

# មាតិកា

១. ការធ្វើបណ្ដឹងឧទ្ធរណ៍

២. ការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍

# ការដោះស្រាយវិវាទតាមផ្លូវតុលាការ

- នីតិវិធីរដ្ឋប្បវេណី
  - នីតិវិធីបណ្ដឹង
    - នីតិវិធីជំនុំជម្រះលើកទី១
    - បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់
    - នីតិវិធីជាស់តឿន
    - នីតិវិធីជំនុំជម្រះសាជាថ្មី
  - នីតិវិធី ចាត់ចែងរក្សាការពារ
  - នីតិវិធីអនុវត្តដោយបង្ខំ
- នីតិវិធីបណ្ដឹងទាក់ទង នឹងឋានៈបុគ្គល
- នីតិវិធីរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹង




| | |
|---|---|
| គន្ថីទី ១ | បទប្បញ្ញត្តិទូទៅ |
| គន្ថីទី ២ | នីតិវិធីនៃការជម្រះក្ដីលើកទី១ |
| គន្ថីទី ៣ | បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ |
| គន្ថីទី ៤ | ការជំនុំជម្រះសាជាថ្មី |
| គន្ថីទី ៥ | នីតិវិធីដាស់តឿន |
| គន្ថីទី ៦ | ការអនុវត្តដោយបង្ខំ |
| គន្ថីទី ៧ | ការចាត់ចែងរក្សាការពារ |
| គន្ថីទី ៨ | អន្តរប្បញ្ញត្តិ |
| គន្ថីទី ៩ | អវសានប្បញ្ញត្តិ |

បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ

# បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

- បណ្តឹងឧទ្ធរណ៍
  - ប្រឆាំងនឹងសាលក្រម
- បណ្តឹងសាទុក្ខ
  - ប្រឆាំងនឹងសាលក្រម/សាលដីកា
- បណ្តឹងជំទាស់
  - ប្រឆាំងនឹងដីកាសម្រេច

# គោលគំនិតនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់៖

១. កែប្រែ ផ្លាស់ប្តូរ ឬលុបចោលសេចក្តីសម្រេចរបស់តុលាការជាន់ទាបដែលមានកំហុស

២. ធ្វើឱ្យមានឯកភាពគ្នាក្នុងការបកស្រាយច្បាប់ដើម្បីធានាឱ្យបាននូវស្ថិរភាពផ្នែកគតិយុត្តនៃជីវភាពរបស់ប្រជាពលរដ្ឋ

(១) ការសម្រេចសេចក្តីចំពោះការទាមទារតាមផ្លូវបណ្តឹង ត្រូវធ្វើឡើងដោយតុលាការ ដែលមានចៅក្រម ជាអ្នកធ្វើសេចក្តីសម្រេច។ ចៅក្រមគឺជាមនុស្សធម្មតាដូចយើងទាំងអស់គ្នាដែរ ដែលជៀសមិនផុតពីការបង្កើតនូវកំហុស ដោយចេតនា ឬអចេតនា ហើយកំហុសនេះអាចបំពានសិទ្ធិរបស់ភាគី និងអាចធ្វើឱ្យបាត់ទំនុកចិត្តជាសាធារណៈចំពោះប្រព័ន្ធតុលាការ ឬ ប៉ះពាល់ដល់យុត្តិធម៌សង្គម។ ហេតុនេះ តម្រូវឱ្យមានប្រព័ន្ធមួយ សម្រាប់ត្រួតពិនិត្យនូវសេចក្តីសម្រេចចុងក្រោយរបស់សាលាដំបូង (តុលាការជាន់ទាប) គឺ **តុលាការនៃបណ្តឹងឧទ្ធរណ៍ (សាលាឧទ្ធរណ៍)** ក្នុងករណីមានបណ្តឹងឧទ្ធរណ៍។

## ការជំនុំជម្រះលើកទី១




សាលាដំបូង

## ការជំនុំជម្រះលើកទី២




សាលាឧទ្ធរណ៍

សាលក្រមចុងក្រោយ

ត្រួតពិនិត្យសាលក្រមចុងក្រោយរបស់សាលាដំបូងឡើងវិញក្នុងករណីមានបណ្ដឹងឧទ្ធរណ៍

(២) បណ្ដឹងឧទ្ធរណ៍ គឺជាបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១របស់សាលាដំបូង ក្នុងគោលបំណងឱ្យតុលាការជាន់ខ្ពស់ លុបចោល ឬ ផ្លាស់ប្ដូរនូវសាលក្រមចុងក្រោយ។




មាត្រា ២៦០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

តុលាការដែលជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ ត្រូវហៅថា **តុលាការនៃបណ្ដឹងឧទ្ធរណ៍** ហើយការជំនុំជម្រះដោយតុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវហៅថា **ការជំនុំជម្រះលើកទី២** ។ ប៉ុន្តែក្នុងករណីមួយចំនួនតាមបញ្ញត្តិពិសេស ដូចជាសេចក្ដីសម្រេចរបស់គណៈមេធាវីជាអាទិ៍ ការជំនុំជម្រះដោយតុលាការនៃបណ្ដឹងឧទ្ធរណ៍ គឺជាការជំនុំជម្រះលើកទី១ ។



# ១. ការធ្វើបណ្តឹងឧទ្ធរណ៍

## ១.១ អ្នកមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ អាចធ្វើឡើងដោយដើមចោទ ឬ ចុងចម្លើយដែលបាត់បង់នូវផលប្រយោជន៍ដោយសារសាលក្រមរបស់សាលាដំបូង ។ ភាគីដែលបាត់បង់ផលប្រយោជន៍ គឺជាភាគីដែលចាញ់ក្តីទាំងស្រុង ឬ មួយផ្នែក ភាគីនោះមានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ហេតុនេះ ភាគីដែលឈ្នះក្តីទាំងស្រុងគ្មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ទេ។ ក្នុងករណីដែលភាគីដែលឈ្នះក្តីទាំងស្រុងធ្វើបណ្តឹងឧទ្ធរណ៍ បណ្តឹងឧទ្ធរណ៍នោះនឹងត្រូវបានតុលាការលើកចោលដោយមូលហេតុផ្ទុយច្បាប់។

មាត្រា ២៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី

«ក»
ដើមចោទ

តុលាការ



សាលក្រមៈ បង្គាប់ឱ្យ
ចុងចម្លើយ «ខ»
បង់ប្រាក់ $ 10,000
មកឱ្យដើមចោទ «ក»



ឧទាហរណ៍ទី១
ពាក្យបណ្តឹងៈ បង្គាប់ឱ្យ
ចុងចម្លើយ «ខ» បង់ប្រាក់
$ 10,000 មកឱ្យដើមចោទ «ក»

«ខ»
ចុងចម្លើយ

ចុងចម្លើយ «ខ» ជាភាគីដែលបាត់បង់ផលប្រយោជន៍
ដោយសារសាលក្រមរបស់សាលាដំបូង
ហេតុនេះ ចុងចម្លើយ «ខ» មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍

«ក»
ដើមចោទ

តុលាការ



«ខ»
ចុងចម្លើយ

សាលក្រម៖
ច្រានចោលការទាមទារ
របស់ដើមចោទ «ក»

ឧទាហរណ៍ទី២
ពាក្យបណ្តឹង៖ បង្គាប់ឱ្យ
ចុងចម្លើយ «ខ» បង់ប្រាក់
$ 10,000 មកឱ្យដើមចោទ «ក»

ដើមចោទ «ក» ជាភាគីដែលបាត់បង់ផលប្រយោជន៍
ដោយសារសាលក្រមរបស់សាលាដំបូង
ហេតុនេះដើមចោទ «ក»មានផលប្រយោជន៍ក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍

«ក»
ដើមចោទ

តុលាការ





«ខ»
ចុងចម្លើយ

ឧទាហរណ៍ទី៣

ពាក្យបណ្ដឹង៖ បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $ 10,000 មកឱ្យដើមចោទ «ក»

សាលក្រម៖ បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $ 8,000 មកឱ្យដើមចោទ «ក»

ក្នុងករណីនេះ ទាំងចុងចម្លើយ «ខ» និងដើមចោទ «ក» សុទ្ធតែជាភាគីដែលបាត់បង់ផលប្រយោជន៍ ហេតុនេះទាំងដើមចោទ និងចុងចម្លើយមានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍។ ក្នុងករណីចុងចម្លើយធ្វើបណ្ដឹងឧទ្ធរណ៍ ដើមចោទក៏អាចធ្វើបណ្ដឹងឧទ្ធរណ៍បានដែរ ប៉ុន្តែបណ្ដឹងឧទ្ធរណ៍ដែលធ្វើឡើងដោយដើមចោទ «ក» ហៅថា **បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ** ។



# ១.២ អំឡុងពេលប្ដឹងឧទ្ធរណ៍

បណ្ដឹងឧទ្ធរណ៍ ត្រូវធ្វើឡើងក្នុងអំឡុងពេល 01 ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនៃការជំនុំជម្រះលើកទី១។




មាត្រា ២៦៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ក្នុងករណីតុលាការ លើកចោល ឬច្រានចោលបណ្ដឹងទាស់ បណ្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងអំឡុងពេល 01 ខែ គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីដីកាសម្រេចច្រានចោល ឬលើកចោលនូវបណ្ដឹងទាស់។



ករណីតុលាការចេញសាលក្រមកំបាំងមុខ ហើយភាគីមិនប្តឹងទាស់ បណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងអំឡុង 01 ខែ គិតចាប់ពីថ្ងៃផុតសិទ្ធិប្តឹងទាស់។



ជាគោលការណ៍អំឡុងពេលធ្វើបណ្តឹងឧទ្ធរណ៍ មិនអាចពន្យារពេលបានឡើយ ប៉ុន្តែក្នុងករណីភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ មិនអាចប្តឹងឧទ្ធរណ៍បានដោយមូលហេតុមិនមែនជាកំហុសរបស់ខ្លួន ភាគីនោះអាចបំពេញនូវសកម្មភាពបណ្តឹងពេលក្រោយបានក្នុងអំឡុង 01 សប្តាហ៍ បន្ទាប់ពីមូលហេតុនោះបានរលត់ ប្រសិនបើភាគីនៅបរទេស អំឡុងពេលនោះមានចំនួន 02 ខែ។



ឧទាហរណ៍ ចុងចម្លើយ «ខ» ទទួលសាលក្រមថ្ងៃទី01.01.2018 ដោយមានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល ០១ ខែ គិតចាប់ពីថ្ងៃទទួលបានសាលក្រម ។ ថ្ងៃទី01.02.2018 ជាថ្ងៃចុងក្រោយនៃសិទ្ធិប្តឹងឧទ្ធរណ៍ «ខ» បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ប៉ុន្តែនៅថ្ងៃនោះមានបាតុកម្មហើយបិទតុលាការ នាំឱ្យមិនអាចទទួលពាក្យបណ្តឹងបាន ក្នុងករណីនេះ អំឡុងពេលប្តឹងឧទ្ធរណ៍ត្រូវបានពន្យារ។




មាត្រា ២៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

# ១.៣ របៀបធ្វើបណ្ដឹងឧទ្ធរណ៍

ដើម្បីប្ដឹងឧទ្ធរណ៍ ភាគីត្រូវដាក់ពាក្យបណ្ដឹងទៅតុលាការដើម (តុលាការនៃការជំនុំជម្រះលើកទី១ ឬសាលាដំបូង)។

«ខ»
ចុងចម្លើយ

ពាក្យបណ្ដឹងឧទ្ធរណ៍ →

តុលាការ



មាត្រា ២៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពី ① អត្តសញ្ញាណរបស់ភាគី ② សញ្ញាណនៃសាលក្រមនៃការជំនុំជម្រះលើកទី១ ③ សេចក្តីដែលប្តឹងចំពោះសាលក្រមនោះ និង ④ មូលហេតុនៃការទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរនូវសាលក្រម។

**① អត្តសញ្ញាណរបស់ភាគី៖**

ដើមបណ្តឹងឧទ្ធរណ៍ ឈ្មោះ «ខ» មានអាសយដ្ឋាន..............

ចុងបណ្តឹងឧទ្ធរណ៍ ឈ្មោះ «ក» មានអាសយដ្ឋាន..............

មាត្រា ២៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

② សញ្ញាណនៃសាលក្រម៖

សាលក្រមរដ្ឋប្បវេណីលេខ ០១ «ក» ភ.ព.វ.វ

ចុះថ្ងៃទី10.10.2016 របស់សាលាដំបូងរាជធានីភ្នំពេញ

ឧទាហរណ៍៖

**សាលក្រមដើម៖**

១. ដើមចោទ «ក» លែងលះចុងចម្លើយ «ខ»

២. បង្គាប់ឱ្យចុងចម្លើយ «ខ» ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L មួយផ្នែកមកឱ្យដើមចោទ «ក» ដោយមូលហេតុបែងចែកទ្រព្យរួម

**③ សេចក្ដីប្ដឹងឧទ្ធរណ៍ ៖**

ប្ដឹងឧទ្ធរណ៍នឹងសេចក្ដីសម្រេចបញ្ចប់ត្រង់ចំណុចទី២ នៃសាលក្រមដើម

**④ មូលហេតុនៃបណ្តឹងឧទ្ធរណ៍ ៖**

សាលក្រមនៃការជំនុំជម្រះលើកទី១ មានកំហុសនីតិវិធីធ្ងន់ធ្ងរ / សាលក្រមនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវ

# ១.៤ កម្មវត្ថុ និងមូលហេតុនៃបណ្ដឹងឧទ្ធរណ៍

## ក. កម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍

កម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ គឺ សាលក្រមចុងក្រោយរបស់សាលាដំបូង ហេតុនេះ សាលក្រមរបៀប មិនអាចក្លាយជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍នោះទេ ពីព្រោះសាលក្រមរបៀប មិនមែនជាសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១។ ម្យ៉ាងវិញទៀត សេចក្ដីសម្រេចរបស់សាលាដំបូងដែលមិនអាចធ្វើឧបាស្រ័យបាន (ដីកាសម្រេចអំពីការតវ៉ាចំពោះការដឹកនាំនីតិវិធី ឬដីកាសម្រេចបង្អង់នីតិវិធីនៃបណ្ដឹងជាអាទិ៍) ឬ សេចក្ដីសម្រេចដែលអាចធ្វើឧបាស្រ័យដោយបណ្ដឹងជំទាស់ (ដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ ឬដីកាសម្រេចលើកចោលពាក្យសុំឱ្យថែរក្សាការពារភស្ដុតាងជាអាទិ៍) ក៏មិនមែនជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ដែរ។

លើសពីនេះទៅទៀត ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ ក្នុងករណី គូភាគីព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សរដោយរក្សាសិទ្ធិប្តឹងសាទុក្ខ ក្រោយពេលតុលាការចេញសាលក្រមចុងក្រោយ ឬ ករណីសាលក្រមចុងក្រោយនោះមានតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី ៥,000,000 (ប្រាំលាន) រៀល ក៏មិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ផងដែរ។

មាត្រា ២៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី

«ក»
ដើមចោទ

«ខ»
ចុងចម្លើយ

ព្រមព្រៀងគ្នា មិនប្តឹងឧទ្ធរណ៍ ដោយទុកសិទ្ធិប្តឹងសាទុក្ខចំពោះសាលក្រមរបស់សាលាដំបូង






សាលក្រមចុងក្រោយដែលមានតម្លៃ
កម្មវត្ថុមិនលើសពី៥លានរៀល៖
បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់
$1,000 មកឱ្យដើមចោទ «ក»



# កម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍

- សាលក្រមចុងក្រោយរបស់សាលាដំបូង

- ✗
  - សាលក្រមរបៀប
  - សេចក្តីសម្រេចដែលមិនអាចធ្វើឧបាស្រ័យ
  - សេចក្តីសម្រេចដែលអាចធ្វើឧបាស្រ័យដោយបណ្តឹងជំទាស់
  - សាលក្រមចុងក្រោយដែលព្រមព្រៀងមិនប្តឹងឧទ្ធរណ៍/ តម្លៃកម្មវត្ថុដែលច្បាប់មិនអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍

## ខ. មូលហេតុនៃបណ្តឹងឧទ្ធរណ៍

មូលហេតុនៃបណ្តឹងឧទ្ធរណ៍ត្រូវបានកំណត់ដាក់លាក់នៅក្នុងច្បាប់ ដែលមាន ៤ ស្ថានភាព៖ (១) សាលក្រមនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវ (២) នីតិវិធីនៅតុលាការនៃការជំនុំជម្រះលើកទី១ នោះផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ (៣) ការលើកបណ្តឹងចោលរបស់សាលាដំបូងមានលក្ខណៈមិនត្រឹមត្រូវ និងមានភាពចាំបាច់ក្នុងការទាញហេតុផលថែមទៀត/ តុលាការដើមទទួលស្គាល់ការទាមទារ ប៉ុន្តែមានកំហុសនីតិវិធីធ្ងន់ធ្ងរដោយមិនបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ (៤) ការជំនុំជម្រះលើកទី១ មានកំហុសចំពោះសមត្ថកិច្ចផ្តាច់មុខ។

## (១) សាលក្រមនៃការជំនុំជម្រះលើកទី១មិនត្រឹមត្រូវ

ជាស្ថានភាពដែលសាលក្រមនោះមានកំហុស ឬសេចក្តីសម្រេចបញ្ចប់នៃសាលក្រមដើមមានលក្ខណៈមិនត្រឹមត្រូវផ្អែកតាមសំអាងហេតុផ្សេងរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ (ភស្តុតាង និងច្បាប់សារធាតុ) ដូចជាអត្ថិភាព ឬនត្ថិភាពនៃកាតព្វកិច្ច ការលើកឡើងអំពីមូលហេតុនៃការរំលាយ ឬលុបចោល ឬមោឃភាពនៃកិច្ចសន្យាជាអាទិ៍។

មាត្រា ២៧៩ កថាខណ្ឌទី ១ ចំណុច «ក» នៃក្រមនីតិវិធីរដ្ឋប្បវេណី

ឧទាហរណ៍៖ ដើមចោទ «ក» បានប្ដឹង «ខ» ទៅសាលាដំបូងឱ្យតុលាការចេញសាលក្រមលេខ០១ "ក" ភ.ព.រ.វ ចុះថ្ងៃទី01.01.2017 ដែលមានខ្លឹមសារថា បង្គាប់ឱ្យចុងចម្លើយ «ខ» ធ្វើនីតិវិធីលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L ទាំងមូល ដោយមូលហេតុរំលាយកិច្ចសន្យាលក់ទិញចុះថ្ងៃទី01.01.2016។ តុលាការយល់ឃើញថា មានមូលហេតុនៃការរំលាយកិច្ចសន្យា ប៉ុន្តែភាគីយល់ថា តាមលក្ខណៈសារធាតុ គ្មានមូលហេតុរំលាយកិច្ចសន្យាទេ។ សាលក្រមនេះត្រូវបាន «ខ» ប្ដឹងឧទ្ធរណ៍។




១. ផ្ទេរកម្មសិទ្ធិពី «ង» ទៅ «ក»

~~២.ផ្ទេរកម្មសិទ្ធិពី «ក» ទៅ «ខ»~~

# សាលាដំបូង

«ក»
ដើមចោទ

«ខ»
ចុងចម្លើយ

រំលាយកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី01.01.2016 ដោយមូលហេតុ «ខ» មិនបានអនុវត្តកាតព្វកិច្ចបង់ប្រាក់តាមកិច្ចសន្យា

បានបង់ប្រាក់ថ្លៃលក់ទិញតាមពេលកំណត់នៅក្នុងកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី01.01.2016

***សេចក្ដីសម្រេចបញ្ចប់៖***

បង្គាប់ឱ្យចុងចម្លើយ «ខ» ធ្វើនីតិវិធីលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L ទាំងមូល ឱ្យទៅ «ក» ដោយមូលហេតុរំលាយកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី01.01.2016

(២) នីតិវិធីនៅតុលាការជាន់ទី១ នោះផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ ជាស្ថានភាពដែលសាលាដំបូងបានជម្រះក្ដីដោយបំពានលើនីតិវិធីដែលច្បាប់បានកំណត់ដូចជាទាក់ទងនឹងការពិនិត្យភស្តុតាង ការបញ្ជូន ការប្រកាសសាលក្រមជាអាទិ៍។

មាត្រា ២៧៩ កថាខណ្ឌទី ១ ចំណុច «ខ» នៃក្រមនីតិវិធីរដ្ឋប្បវេណី

## ទាក់ទងនឹងការពិនិត្យភស្តុតាង

ឧទាហរណ៍ ដើមចោទ «ក» បានដាក់ពាក្យបណ្ដឹងប្ដឹង «ខ» ឱ្យបង់ប្រាក់ $10,000 ដោយផ្អែកលើមូលហេតុនៃកិច្ចសន្យាលក់ទិញកុំព្យូទ័រ ចុះថ្ងៃទី01.01.2016។ តុលាការបានធ្វើការសាកសួរ «គ» ដែលជាសាក្សីរបស់ «ក» នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ដោយផ្អែកលើចម្លើយរបស់សាក្សី «គ» ដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមនោះ តុលាការបានយកជាមូលដ្ឋានសម្រេចឱ្យ «ខ» បង់ប្រាក់ $10,000 ឱ្យទៅ «ក»។ «ខ» បានធ្វើបណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ដោយមូលហេតុការជំនុំជម្រះលើកទី១ មានកំហុសនីតិវិធីធ្ងន់ធ្ងរ។

សាលាដំបូង

01.02.2016

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

រៀបចំការអះអាង ចំណុចវិវាទ និងភស្តុតាង

ការសាកសួរសាក្សី

សាក្សី «គ»៖ នៅថ្ងៃទី 01.01.2016 «ខ» បានទៅហាងលក់Computer របស់«ក» ហើយបានទិញ Computer 06 គ្រឿងតម្លៃ $10,000 ខ្ញុំជាបុគ្គលិក ហើយខ្ញុំជាអ្នកសម្របសម្រួលការលក់ទិញរបស់ពួកគាត់

សាលាដំបូង

«ក» ដើមចោទ

សាក្សី «គ» បញ្ជាក់ពីអត្ថិភាពនៃកិច្ចសន្យាលក់ទិញ

«ខ» ចុងចម្លើយ

B មានកាតព្វកិច្ចត្រូវបង់ប្រាក់ $10,000 តាមកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី01.01.2016

នត្ថិភាពនៃកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី 01.01.2016

***សេចក្តីសម្រេចបញ្ចប់៖***

បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $10,000 ឱ្យទៅដើមចោទ «ក»

## ទាក់ទងនឹងការប្រកាសសាលក្រម

ឧទាហរណ៍ ដើមចោទ «ក» បានដាក់ពាក្យបណ្ដឹងប្ដឹង «ខ» ឱ្យបង់ប្រាក់ $10,000 ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី01.01.2016។ សំណុំរឿង ត្រូវបានចាត់ការដោយចៅក្រម «X» ហើយនៅមុនពេលប្រកាសសាលក្រម ចៅក្រម «X» ត្រូវបានផ្លាស់ចេញទៅបម្រើការនៅតុលាការផ្សេងទៀត។ ចៅក្រម «Y» ត្រូវបានចាត់តាំងឱ្យកាន់សំណុំរឿងនេះបន្ត ហើយផ្អែកលើការទាញហេតុផលរបស់ចៅក្រម «X» ចៅក្រម «Y» បានប្រកាសសាលក្រម។ B បានធ្វើបណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ដោយមូលហេតុការជំនុំជម្រះលើកទី១ មានកំហុសនីតិវិធីធ្ងន់ធ្ងរ។

មាត្រា ១៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី




ចៅក្រម «Y» ប្រកាសដោយមិនធ្វើការទាញហេតុផលម្ដងទៀត

***សេចក្ដីសម្រេចបញ្ចប់៖***

បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $10,000 ឱ្យទៅដើមចោទ «ក»

(៣) ការលើកបណ្ដឹងចោលរបស់សាលាដំបូងមានលក្ខណៈមិនត្រឹមត្រូវ និងមានភាពចាំបាច់ក្នុងការទាញហេតុផលថែមទៀត

ជាស្ថានភាពដែលសាលាដំបូងបានលើកចោលពាក្យបណ្ដឹងរបស់ដើមចោទដោយសាលក្រម មិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ដោយមូលហេតុពាក្យបណ្ដឹងរបស់ដើមចោទផ្ទុយច្បាប់មិនអាចកែតម្រូវបាន។

មាត្រា ២៨០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ឧទាហរណ៍ ដើមចោទ «ក» បានដាក់ពាក្យបណ្តឹងប្តឹង «ខ» ឱ្យសងប្រាក់ $10,000 ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ដែលកំណត់ពេលសងនៅថ្ងៃទី01.01.2018។ សាលាដំបូងបានលើកចោលពាក្យបណ្តឹងដោយសាលក្រម ដោយមូលហេតុ គ្មានផលប្រយោជន៍នៃបណ្តឹង។ «ក» បានធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ដោយមូលហេតុថាសាលក្រមលើកចោលនេះមិនត្រឹមត្រូវ។

(៤) ការជំនុំជម្រះលើកទី១ មានកំហុសចំពោះសមត្ថកិច្ចផ្តាច់មុខជាស្ថានភាពដែលសាលាដំបូង បានចេញសាលក្រមចំពោះការទាមទារដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ដោយសារច្បាប់កំណត់អំពីសមត្ថកិច្ចផ្តាច់មុខចំពោះករណីណាមួយ ដូចជាបណ្តឹងលែងលះ បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃបុត្តភាពជាអាទិ៍។

មាត្រា ២៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ឧទាហរណ៍ ដើមចោទ «ក» បានដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់កូន ដោយយក «ខ» ជាចុងចម្លើយ ។ «ក» មានលំនៅឋាននៅខេត្តកំពង់ចាម «ខ» មានវត្តមានចុងក្រោយនៅប្រទេសកម្ពុជានៅក្នុងខេត្តសៀមរាប ប៉ុន្តែបានចាកចេញទៅបរទេសជាង ១០ ឆ្នាំមកហើយ។ សាលាដំបូងខេត្តសៀមរាប បានចាត់ការពាក្យបណ្ដឹងនេះហើយសម្រេចឱ្យទទួលស្គាល់ «ក» ជាកូនរបស់ «ខ»។ «ខ» បានប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ដោយមូលហេតុថាតុលាការខេត្តសៀមរាបមិនមានសមត្ថកិច្ចក្នុងការចាត់ការបណ្ដឹង។

«ក»
ដើមចោទ

តុលាការ




«ខ»
ចុងចម្លើយ

ទទួលស្គាល់ ដើមចោទ«ក» ជាកូនរបស់ចុងចម្លើយ «ខ»

គ្មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើរឿងក្ដីនេះទេ




តុលាការ

ជំនុំជម្រះលើរឿងក្ដីទាមទារឱ្យ
ទទួលស្គាល់កូន

***សេចក្ដីសម្រេចបញ្ចប់៖***

ទទួលស្គាល់ដើមចោទ «ក» ជាកូនរបស់ចុងចម្លើយ «ខ»

ការជំនុំជម្រះលើបណ្តឹងទាមទារឱ្យទទួលស្គាល់កូន គឺជាសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូង នៃលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គល។ ក្នុងករណីលំនៅឋាន ឬ ទីសំណាក់របស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលមិនអាចកំណត់បានដោយសារករណីជាក់ស្តែងនីមួយៗ ច្បាប់សន្មតថា តុលាការដែលមានសមត្ថកិច្ចលើរឿងក្តីប្រភេទនេះ គឺសាលាដំបូងរាជធានីភ្នំពេញ។



មាត្រា ៥ កថាខណ្ឌទី ៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

# ១.៥ អានុភាពនៃបណ្ដឹងឧទ្ធរណ៍

## ក. ការបង្អាក់ការចូលជាស្ថាពរនៃសាលក្រម

អានុភាពបង្អាក់ការចូលជាស្ថាពរនៃសាលក្រម ជាស្ថានភាពដែលរាំងការចូលជាស្ថាពរនៃសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ ដោយសារអានុភាពនៃការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។




03.02.2017
03.03.2017
សាលក្រមចូលជាស្ថាពរ
បង្អាក់ការចូលជាស្ថាពរ
ទទួលលិខិតសាលក្រម
អំឡុងពេលប្តឹងឧទ្ធរណ៍


03.02.2017
03.03.2017
បង្អាក់ការចូលជាស្ថាពរ
ដាក់ពាក្យបណ្តឹងឧទ្ធរណ៍

ប៉ុន្តែក្នុងករណីសាលក្រមដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន សាលក្រមនោះ មានអានុភាពអនុវត្តបាន ទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ។




មានអានុភាពអនុវត្តដោយមិនរង់ចាំការចូល
ជាស្ថាពរនៃសាលក្រម

## ខ. ការផ្ទេរការជម្រះក្ដី

បណ្ដឹងឧទ្ធរណ៍ ដែលបានធ្វើឡើងក្នុងអំឡុងពេលដែលបានកំណត់ មានអានុភាពផ្ទេរការទាមទារពីសាលាដំបូងទៅសាលាឧទ្ធរណ៍ មានន័យថា វិវាទរវាងដើមចោទ និងចុងចម្លើយនៅតុលាការនៃការជំនុំជម្រះក្ដីលើកទី១ មិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការនៃការជំនុំជម្រះលើកទី១ទៀតទេ ពោលគឺស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍។

ឧទាហរណ៍ ដើមចោទ «ក» បានប្ដឹង «ខ» ឱ្យបង់ប្រាក់ចំនួន $10,000 មកឱ្យខ្លួន។ សាលាដំបូងសម្រេចទទួលស្គាល់ការទាមទាររបស់ «ក»។ «ខ» បានប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមរបស់សាលាដំបូង ដោយយល់ឃើញថា សាលក្រមនេះមិនត្រឹមត្រូវ។ ក្នុងករណីនេះ ការសម្រេចអំពីវិវាទនៃសិទ្ធិទាមទារប្រាក់ $10,000 ត្រូវផ្ទេរពីសមត្ថកិច្ចរបស់តុលាការជាន់ទាបទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍។

តុលាការ




តុលាការមានសមត្ថកិច្ច

តុលាការ




សាលក្រម៖ បង្គាប់ឱ្យចុងចម្លើយ «ខ»
បង់ប្រាក់ $ 10,000 មកឱ្យដើមចោទ «ក»

សាលក្រមនេះ «ខ» ប្ដឹងឧទ្ធរណ៍

# គ. អវិភាគភាពនៃបណ្ដឹងឧទ្ធរណ៍

បណ្ដឹងឧទ្ធរណ៍ ដែលបានធ្វើឡើងក្នុងអំឡុងពេលដែលច្បាប់បានកំណត់ មានអានុភាពបង្អាក់ការចូលជាស្ថាពរនៃសាលក្រមចុងក្រោយរបស់សាលាដំបូងទាំងមូល ទោះបីជាបណ្ដឹងឧទ្ធរណ៍ធ្វើឡើងចំពោះតែផ្នែកណាមួយនៃសាលក្រមចុងក្រោយរបស់សាលាដំបូងក៏ដោយ។



ឧទាហរណ៍ សាលក្រមរបស់សាលាដំបូងលេខ០១ "ក" ភ.ព.រ.រ ចុះថ្ងៃទី01.01.2017 របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារ៖

(១) «ក» និង «ខ» លែងលះគ្នា

(២) បង្គាប់ឱ្យចុងចម្លើយ «ខ» ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L មួយផ្នែកមកឱ្យដើមចោទ «ក» ដោយមូលហេតុបែងចែកទ្រព្យសម្បត្តិរួម

(៣) ដើមចោទ «ក» ជាអ្នកមានអំណាចមេបាលើកូន «គ»

(៤) បង្គាប់ឱ្យចុងចម្លើយ «ខ» ប្រគល់កូន «គ» មកឱ្យដើមចោទ «ក»

«ខ» ប្តឹងឧទ្ធរណ៍ចំណុចទី២ ទី៣ និងទី៤

ក្នុងករណី «ខ» ធ្វើបណ្ដឹងឧទ្ធរណ៍តែចំណុចទី២ ទី៣ និងទី៤ នាំឱ្យសាលក្រមទាំងមូលមិនចូលជាស្ថាពរ ហេតុនេះ ទោះបីជាចំណុចទី១ «ខ» មិនប្ដឹងឧទ្ធរណ៍ក៏ដោយ ក៏ចំណុចទី១នេះ មិនចូលជាស្ថាពរដែរ នេះហៅថា **អវិភាគភាពនៃបណ្ដឹងឧទ្ធរណ៍** ។




សាលក្រមទាំងមូលមិនចូលជាស្ថាពរដោយសារ
អានុភាពនៃបណ្ដឹងឧទ្ធរណ៍

ប៉ុន្តែក្នុងករណីតុលាការបានចេញសាលក្រម ហើយភាគីបានព្រមព្រៀងគ្នា មិនប្ដឹងឧទ្ធរណ៍ចំពោះផ្នែកណាមួយនៃការទាមទារ ឬភាគីទាំងសងខាងលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍ និងសិទ្ធិប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ចំពោះផ្នែកណាមួយនៃការទាមទារ នាំឱ្យផ្នែកនោះនៃសាលក្រមចុងក្រោយ ត្រូវចូលជាស្ថាពរ។

មាត្រា ២៦០ កថាខណ្ឌទី១ ចំណុច «ក»
និង មាត្រា ២៧០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី



តុលាការ

«ក» ដើមចោទ → «ខ» ចុងចម្លើយ

១. បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $10,000 ឱ្យដើមចោទ «ក»

២. បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ក្នុងអត្រា10%/ឆ្នាំនៃទឹកប្រាក់ $10,000 គិតចាប់ពីថ្ងៃទី 01.01.2017 រហូតសងរួច

៣. បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $5000 មកឱ្យដើមចោទ «ក»

# តុលាការ

## សេចក្តីសម្រេចបញ្ជប់៖

១. បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $8,000 ឱ្យដើមចោទ «ក»

២. បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ក្នុងអត្រា 10%/ឆ្នាំនៃទឹកប្រាក់ $8,000 គិតចាប់ពីថ្ងៃទី 01.01.2017 រហូតសងរួច

៣. បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $5000 មកឱ្យដើមចោទ «ក»

ដើមចោទ និងចុងចម្លើយ បានព្រមព្រៀង មិនធ្វើបណ្តឹងឧទ្ធរណ៍ និងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះចំណុចទី១ និងទី២ នៃសេចក្តីសម្រេចបញ្ចប់របស់សាលក្រមនៃការជំនុំជម្រះលើកទី១ ប៉ុន្តែចំពោះចំណុចទី៣ ចុងចម្លើយអាចប្តឹងឧទ្ធរណ៍ ។

ក្នុងករណីនេះ ចំណុចទី១ និងទី២ ត្រូវចូលជាស្ថាពរ ដោយមិនរង់ចាំផុតអំឡុងពេលនៃការប្ដឹងឧទ្ធរណ៍ទេ ហេតុនេះ ការព្រមព្រៀងមិនប្ដឹងឧទ្ធរណ៍និងប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនូវចំណុចណាមួយ ចំណុចដែលបានព្រមព្រៀងនោះនឹងចូលជាស្ថាពរ ទោះបីជាចំណុចផ្សេងទៀត ភាគីបានប្ដឹងឧទ្ធរណ៍ក៏ដោយ។

ចំណុចទី១ និងទី២ ចូលជាស្ថាពរ

ព្រមព្រៀងមិនប្ដឹងឧទ្ធរណ៍/
បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ




ចំណុចប្ដឹងឧទ្ធរណ៍

ចំណុចទី៣ មិនចូលជាស្ថាពរដោយអានុភាពនៃបណ្ដឹងឧទ្ធរណ៍

# ១.៦ បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ

បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺជាឧបាស្រ័យដោយភ្ជាប់ជាមួយនឹងបណ្ដឹងឧទ្ធរណ៍របស់ភាគីម្ខាងទៀតចំពោះចំណុចដែលចុងបណ្ដឹងឧទ្ធរណ៍បាត់បង់ផលប្រយោជន៍ ។

ឧទាហរណ៍ ដើមចោទ «ក» ទាមទារទៅសាលាដំបូងឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $10,000 ហើយតុលាការបានសម្រេចឱ្យ $9,000 ក្នុងករណីនេះ ដើមចោទ «ក» អាចប្ដឹងឧទ្ធរណ៍បានចំពោះសាលក្រមនេះ ប៉ុន្តែ «ក» មិនបានធ្វើបណ្ដឹងឧទ្ធរណ៍ទេ ។ បន្ទាប់មកចុងចម្លើយ «ខ» ធ្វើបណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ពេលនោះដើមចោទក៏បានធ្វើបណ្ដឹងឧទ្ធរណ៍ ដែលបណ្ដឹងឧទ្ធរណ៍របស់ដើមចោទហៅថា **បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ** ។


សាលាដំបូងរាជធានីភ្នំពេញ
និង
អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
តុលាការ
ប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ
②
សាលាឧទ្ធរណ៍
តុលាការ
«ក»
ដើមចោទ
ទាមទារឱ្យ «ខ»
បង់ប្រាក់ $10,000
①
ប្ដឹងឧទ្ធរណ៍
«ខ»
ចុងចម្លើយ
សាលក្រម៖ បង្គាប់ឱ្យចុងចម្លើយ
«ខ» បង់ប្រាក់ $9,000 មក
ឱ្យដើមចោទ «ក»

បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ អាចធ្វើបាននៅគ្រប់ដំណាក់កាលនៃនីតិវិធីបណ្តឹងឧទ្ធរណ៍ ប៉ុន្តែត្រូវធ្វើនៅមុនពេលការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍បានបញ្ចប់ មានន័យថា ទោះបីជាសិទ្ធិប្តឹងឧទ្ធរណ៍ត្រូវបានរលត់ក៏ដោយ (ហួសអំឡុងពេលប្តឹងឧទ្ធរណ៍) ក៏ចុងបណ្តឹងឧទ្ធរណ៍អាចធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ។

មាត្រា ២៧០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ដាក់ពាក្យបណ្តឹងឧទ្ធរណ៍

ការទាញហេតុផលដោយផ្ទាល់មាត់

ប្រកាសសាលដីកា

អំឡុងពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ

សិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំត្រូវបានរលត់

អំឡុងពេលធ្វើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ដូចគ្នានឹងបណ្ដឹងឧទ្ធរណ៍ដែរ ពោលគឺ ០១ ខែ គិតចាប់ពីថ្ងៃទទួលបានលិខិតសាលក្រម ប៉ុន្តែទោះបីជា អំឡុងពេល ០១ ខែ បានកន្លងផុតក៏ដោយ ក៏អាចធ្វើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំដែរ ។ ក្នុងករណី បណ្ដឹងឧទ្ធរណ៍ត្រូវ បាត់បង់អានុភាព នៅពេលដែលតុលាការនៃបណ្ដឹងឧទ្ធរណ៍លើកចោលបណ្ដឹងឧទ្ធរណ៍ ឬដើមបណ្ដឹងឧទ្ធរណ៍បានដកពាក្យបណ្ដឹង បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនឹងបាត់បង់អានុភាពដែរ ប្រសិនបើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនោះធ្វើឡើងហួសអំឡុងពេលប្ដឹងឧទ្ធរណ៍។

មាត្រា ២៧០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

# បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដាក់ក្នុងអំឡុងពេលហួសសិទ្ធិប្តឹងឧទ្ធរណ៍

«ខ» ដើមបណ្តឹងឧទ្ធរណ៍

① ប្តឹងឧទ្ធរណ៍

② ប្តឹងឧទ្ធរណ៍បន្ទាប់បន្សំ

«ក» ចុងបណ្តឹងឧទ្ធរណ៍




ផុតសិទ្ធិប្តឹងឧទ្ធរណ៍

អំឡុងពេលប្តឹងឧទ្ធរណ៍

ដកពាក្យបណ្តឹង/
តុលាការលើកចោលបណ្តឹង

① ប្តឹងឧទ្ធរណ៍

② ប្តឹងឧទ្ធរណ៍បន្ទាប់បន្សំ

ប៉ុន្តែក្នុងករណីដែលបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ បានធ្វើឡើងដោយឯករាជ្យ ទោះបីជាតុលាការលើកចោល ឬ ដើមបណ្តឹងឧទ្ធរណ៍ដកពាក្យបណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏មិនប៉ះពាល់ដល់បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដែរ (មិនបាត់បង់អានុភាព) ក្នុងករណីនេះ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ នឹងក្លាយជាបណ្តឹងឧទ្ធរណ៍ឯករាជ្យ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍នឹងបន្តចាត់ការលើបណ្តឹងឧទ្ធរណ៍នោះ។

មាត្រា ២៧០ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

# បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដាក់ក្នុងអំឡុងពេលកំណត់ប្តឹងឧទ្ធរណ៍



## ការបង់ពន្ធដាក់ពាក្យបណ្ដឹងឧទ្ធរណ៍/បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ

ពន្ធដាក់ពាក្យសុំនៅក្នុងនីតិវិធីបណ្ដឹងឧទ្ធរណ៍ ត្រូវគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹង ដែលមានចំនួន 1.5 ដង នៃពន្ធដាក់ពាក្យសុំនៅតុលាការជាន់ទាប។

បញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ហេតុនេះ នៅពេលដែលចុងបណ្ដឹងឧទ្ធរណ៍ ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ក៏ត្រូវបង់ពន្ធដាក់ពាក្យសុំទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនោះផងដែរ។

មាត្រា ៦១ កថាខណ្ឌទី១ និងទី៣ និងមាត្រា ២៧០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ឧទាហរណ៍៖ ដើមចោទ «ក» បានប្ដឹងទាមទារឱ្យ «ខ» បង់ប្រាក់ $10,000 ការប្រាក់ 10%/ឆ្នាំ ការប្រាក់យឺតយ៉ាវ 15%/ឆ្នាំ។ សេចក្ដីសម្រេចបញ្ចប់នៃសាលក្រម មានខ្លឹមសារថា ទី១ ឱ្យ «ខ» បង់ប្រាក់ $8,000 ទី២ ការប្រាក់ 10%/ឆ្នាំ និងទី៣ ការប្រាក់យឺតយ៉ាវ 15%/ឆ្នាំ។ «ខ» បានប្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចទាំងមូល ហើយ «ក» បានធ្វើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះចំណុចទី ១។




មាត្រា ២៧០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

# ការបង់ពន្ធដាក់ពាក្យបណ្តឹងឧទ្ធរណ៍របស់ «ខ»

តម្លៃកម្មវត្ថុនៃបណ្តឹង ដែលជាមូលដ្ឋានក្នុងការគណនាពន្ធដាក់ពាក្យសុំ គឺកម្រិតត្រឹមតែការទាមទារចម្បងតែប៉ុណ្ណោះ រីឯការទាមទារបន្ទាប់បន្សំ មិនត្រូវក្លាយជាតម្លៃកម្មវត្ថុនៃបណ្តឹងនោះទេ។ ហេតុនេះ មានតែទឹកប្រាក់ $10,000 ប៉ុណ្ណោះ ដែលត្រូវយកមកគណនា ឯការបង់ការប្រាក់ 10%/ឆ្នាំ និងការប្រាក់យឺតយ៉ាវ 15%/ឆ្នាំ មិនត្រូវយកមកគណនាឡើយ ព្រោះជាការទាមទារបន្ទាប់បន្សំ។ ក្នុងករណីនេះ «ខ» ត្រូវបង់ពន្ធដាក់ពាក្យសុំដែលមានតម្លៃស្មើនឹងកម្មវត្ថុនៃបណ្តឹងដើម គឺ $10,000 ព្រោះ «ខ» បានធ្វើការទាមទារចំពោះសាលក្រមទាំងមូល។

តម្លៃកម្មវត្ថុនៃបណ្តឹង= $10,000 = ៛40,000,000
( កំណត់យក $1=៛4,000 )

ពន្ធដាក់ពាក្យសុំ= ?

$Y_{1(Max)}$ = ( 10,000,000/100,000 ) x 1,000= 100,000

$Y_2$= [( 40,000,000-10,000,000 )/100,000]x 700= 210,000

Y= $Y_{1(Max)}$ +$Y_2$= 100,000+210,000= 310,000

ពន្ធដាក់សុំនៃបណ្តឹងឧទ្ធរណ៍= Y x 1.5= 310,000 x 1.5= **៛465,000**

# ការបង់ពន្ធដាក់ពាក្យបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំរបស់ «ក»

ការទាមទារក្នុងបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំរបស់ «ក» ចំនួន $ 2,000 ហេតុនេះ តម្លៃកម្មវត្ថុនៃបណ្ដឹង ដែលជាមូលដ្ឋាននៅក្នុងការគណនាពន្ធដាក់ពាក្យសុំគឺ $2,000 មិនមែន $10,000 នោះទេ ព្រោះចំណុចដែល «ក» បានធ្វើការទាមទារនៅក្នុងបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺចំនួនទឹកប្រាក់ $2,000 ដែលនៅសល់ពីការសម្រេចរបស់តុលាការជាន់ទាបដែលបានសម្រេចសិទ្ធិឱ្យ «ក» ចំនួន $8,000 ស្របពេលដែលបានធ្វើការទាមទារ $10,000។

តម្លៃកម្មវត្ថុនៃបណ្ដឹង= $2,000 = ៛8,000,000
( កំណត់យក $1=៛4,000 )

ពន្ធដាក់ពាក្យសុំ= ?

$Y_1$= ( 8,000,000/100,000 ) x 1,000= 80,000

ពន្ធដាក់សុំនៃបណ្ដឹងឧទ្ធរណ៍= $Y_1$ x 1.5= 80,000 x1.5= **៛120,000**

# ១. ៧ ការដកបណ្ដឹងឧទ្ធរណ៍

ទោះបីជាបណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់រួចហើយក៏ដោយ ភាគីនៅតែមានសិទ្ធិនៅក្នុងការដកពាក្យបណ្ដឹងវិញ នៅពេលណាក៏បាន រហូតដល់ពេលដែលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវបានប្រកាស ដោយមិនចាំបាច់ទទួលការយល់ព្រមពីចុងបណ្ដឹងឧទ្ធរណ៍។



ការដកពាក្យបណ្តឹងឧទ្ធរណ៍ គឺជាការដកចេញនូវឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី១ ហើយអានុភាពនៃការដកបណ្តឹងឧទ្ធរណ៍ នាំឱ្យនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវបានបញ្ចប់ និងត្រូវបានចាត់ទុកថាគ្មានបណ្តឹងឧទ្ធរណ៍តាំងពីដើម ហើយសាលក្រមនៃការជំនុំជម្រះលើកទី១ ត្រូវចូលជាស្ថាពរ តាំងពីថ្ងៃផុតអំឡុងពេលនៃការប្តឹងឧទ្ធរណ៍។

មាត្រា ២៦៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ទទួលលិខិត
សាលក្រម

01.03.2018

«ខ» ប្ដឹងឧទ្ធរណ៍

28.03.2018

02.04.2018

«ខ» ដកពាក្យបណ្ដឹងឧទ្ធរណ៍

10.06.2018

សាលក្រមនៃការជំនុំជម្រះ
លើកទី១ ចូលជាស្ថាពរ

អានុភាពនៃការដកពាក្យបណ្ដឹងនាំឱ្យសាលក្រមនៃការជំនុំជម្រះលើកទី១ ចូលជាស្ថាពរតាំងពីអំឡុងពេលប្ដឹងឧទ្ធរណ៍បានកន្លងហួស

# ការសងពន្ធដាក់ពាក្យសុំពាក់កណ្ដាល

នៅក្នុងករណីដែលបណ្ដឹងឧទ្ធរណ៍ ត្រូវបានដកមុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង នៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ ដើមបណ្ដឹងឧទ្ធរណ៍ អាចដាក់ពាក្យសុំឱ្យសងពាក់កណ្ដាលនៃពន្ធដាក់ពាក្យសុំ។

ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍

ដកពាក្យបណ្ដឹងឧទ្ធរណ៍

ការទាញហេតុផលដោយផ្ទាល់មាត់

«ខ»
ដើមបណ្ដឹងឧទ្ធរណ៍




សងពន្ធដាក់ពាក្យសុំពាក់កណ្ដាល

ឧទាហរណ៍៖ ភាគី «ខ» បានប្តឹងឧទ្ធរណ៍ទាំងមូលចំពោះសេចក្តីសម្រេចរបស់តុលាការជាន់ទាបដែលបានសម្រេចឱ្យ «ខ» បង់ប្រាក់ $10,000 ឱ្យទៅដើមចោទ «ក»។

ប្រសិនបើ «ខ» ប្តឹងឧទ្ធរណ៍ «ខ» ត្រូវបង់ពន្ធដាក់ពាក្យសុំនៃបណ្តឹងឧទ្ធរណ៍ចំនួន ៛465,000។

ករណីនេះប្រសិនបើ «ខ» ដកបណ្តឹងឧទ្ធរណ៍ មុនពេលទាញហេតុផលដោយផ្ទាល់មាត់ «ខ» អាចដាក់ពាក្យសុំឱ្យសងពន្ធខាងលើនេះពាក់កណ្តាលវិញ ដែលមានចំនួនស្មើនឹង **៛232,500**។

# ២. ការជំនុំជម្រះបណ្តឹងឧទ្ធរណ៍

## ២.១ ការទទួល /ពិនិត្យ/បញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍

### (១) ការទទួលពាក្យបណ្តឹងឧទ្ធរណ៍

ភាគីដែលខូចប្រយោជន៍ អំពីសេចក្តីសម្រេចរបស់តុលាការនៃការជំនុំជម្រះលើកទី១ អាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការដើម (សាលាដំបូង)។ តុលាការដើមនឹងបញ្ជូនសំណុំឯកសារទាំងនេះមកតុលាការនៃបណ្តឹងឧទ្ធរណ៍ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវទទួលពាក្យបណ្តឹងឧទ្ធរណ៍ ពិនិត្យចាត់ការទៅតាមលក្ខខណ្ឌច្បាប់។

តុលាការដើម (សាលាដំបូង) ជាតុលាការដែលទទួលយកពាក្យបណ្ដឹងឧទ្ធរណ៍របស់ភាគី និងធ្វើការបញ្ជូនពាក្យបណ្ដឹងនោះជាមួយនឹងសំណុំរឿងក្ដីដែលពាក់ព័ន្ធ ទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ ហេតុនេះ តុលាការដើម ពុំមានសមត្ថកិច្ចពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍ ដូចជា មូលហេតុនៃបណ្ដឹងឧទ្ធរណ៍ អំឡុងពេលនៃការធ្វើបណ្ដឹងឧទ្ធរណ៍ ការបង់ពន្ធដាក់ពាក្យសុំជាអាទិ៍នោះទេ ពោលគឺ ត្រឹមតែទទួលពាក្យបណ្ដឹង និងបញ្ជូនទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍តែប៉ុណ្ណោះ។

ធ្វើចំណាត់ការលើបណ្តឹងឧទ្ធរណ៍

បញ្ជូនពាក្យបណ្តឹង

ពិនិត្យពាក្យបណ្តឹង

ទទួលពាក្យបណ្តឹង






ភាគីដែលខូចផលប្រយោជន៍

① បណ្តឹងឧទ្ធរណ៍

② បញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍

## (២) ការពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍

នៅពេលតុលាការនៃបណ្ដឹងឧទ្ធរណ៍ បានទទួលពាក្យបណ្ដឹងឧទ្ធរណ៍ តុលាការនឹងពិនិត្យទៅលើពាក្យបណ្ដឹងឧទ្ធរណ៍នោះ នូវចំណុចជាលក្ខណៈទម្រង់ចំនួន ០២ គឺ ៖

ចំណុចទី១ ① ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានភាគីហើយឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ② សញ្ញាណសាលក្រមនៃការជនុំជម្រះលើកទី១ និង ③ សេចក្ដីដែលប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ (បញ្ជាក់អំពីចំណុចដែលត្រូវប្ដឹងឧទ្ធរណ៍)។

ចំណុចទី២ ការបង់ប្រាក់ប្រដាប់ក្ដី

មាត្រា ២៦៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ក្នុងករណីមានចំណុចខ្វះខាត ដូចជាមិនបង់ពន្ធដាក់ពាក្យសុំ ឬ ខ្វះអាសយដ្ឋានជាអាទិ៍ តុលាការនឹងបង្គាប់ឱ្យកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ ប្រសិនបើភាគីមិនបានកែតម្រូវក្នុងអំឡុងសមរម្យទេ តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវចេញដីកាសម្រេចលើកចោលបណ្ដឹងឧទ្ធរណ៍ ។

មាត្រា ២៦៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

## (៣) ការបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍

ក្រោយពីតុលាការពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍ ក្នុងករណីពាក្យបណ្ដឹងបានបំពេញលក្ខខណ្ឌតាមច្បាប់ តុលាការនឹងបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍ទៅចុងបណ្ដឹងឧទ្ធរណ៍ ដើម្បីឱ្យចុងបណ្ដឹងឧទ្ធរណ៍បានដឹង និងត្រៀមខ្លួនក្នុងការឆ្លើយតបជាមួយនឹងបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងឧទ្ធរណ៍ ។




មាត្រា ២៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

# ២.២ វិសាលភាពនៃការវិនិច្ឆ័យលើបណ្តឹងឧទ្ធរណ៍

តុលាការនៃបណ្តឹងឧទ្ធរណ៍អាចលុបចោល ឬផ្លាស់ប្តូរសាលក្រមចុងក្រោយ នៃការជំនុំជម្រះលើកទី១ ត្រឹមកម្រិតនៃការទាមទារក្នុងបណ្តឹងឧទ្ធរណ៍ (គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី) តែប៉ុណ្ណោះ។ ហេតុនេះ ចំណុចណាមួយនៃសាលក្រមនៃការជំនុំជម្រះលើកទី១ ដែលមិនត្រូវបានប្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍មិនអាចសម្រេចបាននោះទេ។




មាត្រា ២៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ម្យ៉ាងវិញទៀត ដើមបណ្តឹងឧទ្ធរណ៍ មិនអាចទទួលនូវសាលដីកាដែលខូចប្រយោជន៍ច្រើនជាងអ្វីដែលមានសម្រេចនៅក្នុងសាលក្រម នៃការជំនុំជម្រះលើកទី១នោះទេ (គោលការណ៍នៃការហាមឃាត់ការផ្លាស់ប្តូរដោយខូចផលប្រយោជន៍) លើកលែងតែមានបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។






ទាមទារឱ្យ « ខ »
បង់ប្រាក់ $10,000

សាលក្រមដើម៖ បង្គាប់ឱ្យចុងចម្លើយ
« ខ » បង់ប្រាក់ $ 8,000 មក
ឱ្យដើមចោទ « ក »

« ខ »
ដើមបណ្តឹងឧទ្ធរណ៍

ប្តឹងឧទ្ធរណ៍ →

« ក »
ចុងបណ្តឹងឧទ្ធរណ៍

គោលបំណងរបស់ដើមបណ្តឹងឧទ្ធរណ៍
ចង់ឱ្យតុលាការលុបចោលការសម្រេច
ឱ្យបង់ប្រាក់ $ 8,000

តុលាការនៃបណ្តឹងឧទ្ធរណ៍ អាចសម្រេចលុបចោល ឬផ្លាស់ប្តូរសាលក្រមដើមដែលមានទំហំមិនឱ្យខូចប្រយោជន៍របស់ដើមបណ្តឹងឧទ្ធរណ៍លើសពី $ 8,000 នោះទេ




ប៉ុន្តែក្នុងករណី ចុងបណ្ដឹងឧទ្ធរណ៍បានធ្វើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ តុលាការនៃបណ្ដឹងឧទ្ធរណ៍ អាចសម្រេចឱ្យដើមបណ្ដឹងឧទ្ធរណ៍ខូចផលប្រយោជន៍លើសពី \$8,000 មានន័យថា ដោយសារតែមានបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះចំនួនទឹកប្រាក់ \$2,000 ហេតុនេះ ដើមបណ្ដឹងឧទ្ធរណ៍អាចខូចខាតផលប្រយោជន៍ចំនួន \$10,000 ប្រសិនបើ តុលាការនៃបណ្ដឹងឧទ្ធរណ៍ ទទួលស្គាល់បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំរបស់ចុងបណ្ដឹងឧទ្ធរណ៍។

# ២.៣ ការទាញហេតុផលដោយផ្ទាល់មាត់

(១) តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃបណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រមដើម ដោយចេញសាលដីកាហេតុនេះ ដើម្បីអាចវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវបាន តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់។

ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើត្រឹមទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្ដូរសាលក្រមនៃការជំនុំជម្រះលើកទី១តែប៉ុណ្ណោះ។

ការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ តម្រូវឱ្យភាគីធ្វើសេចក្ដីថ្លែងការណ៍ អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃការជំនុំជម្រះលើកទី១។

មាត្រា ២៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

(២) ការទាញហេតុផលដោយផ្ទាល់មាត់ នៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ គឺជាការបន្តការវិនិច្ឆ័យ ដោយបើកឡើងវិញនូវការទាញហេតុផលដោយផ្ទាល់មាត់ជាថ្មី ដែលត្រូវបានបញ្ចប់ម្ដងរួចហើយ នៅក្នុងការជំនុំជម្រះលើកទី១ ដូចនេះ សកម្មភាពបណ្ដឹង (ការអះអាងអង្គហេតុ ការស្នើសុំឱ្យពិនិត្យភស្តុតាង ការសារភាព ជាអាទិ៍) ដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី១ មានអានុភាពនៅក្នុងការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍។



ហេតុនេះ នៅក្នុងការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ តុលាការនៃបណ្ដឹងឧទ្ធរណ៍ មិនអនុញ្ញាតឱ្យដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន (ភស្តុតាង) បន្ថែម ឬ ថ្មីនោះទេ ។

ការជំនុំជម្រះលើកទី១ ការជំនុំជម្រះលើកទី២



ភស្តុតាង X មិនត្រូវបានដាក់នោះទេ

ស្នើសុំដាក់ភស្តុតាង X

ភស្តុតាង X មិនត្រូវបានអនុញ្ញាតឱ្យដាក់នោះទេ

មាត្រា ២៧៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ប៉ុន្តែភាគីអាចត្រូវបានផ្តល់ឱកាសឱ្យដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនដែលមិនបានដាក់នៅក្នុងការជំនុំជម្រះលើកទី១ ប្រសិនបើមធ្យោបាយតទល់ ឬ ការពារខ្លួន (ភស្តុតាង) នោះ មិនផ្ទុយនឹងបញ្ញត្តិនៃមាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ឧទាហរណ៍ នៅក្នុងការជំនុំជម្រះលើកទី១ ដើមចោទ បានដាក់ពាក្យសុំឱ្យសាកសួរសាក្សី «គ» ប៉ុន្តែដោយសារ សាក្សី «គ» មានជំងឺធ្ងន់ធ្ងរត្រូវទៅព្យាបាលនៅបរទេស ដោយមិនដឹងពេលណាអាចត្រឡប់មកវិញបាន ហេតុនេះ សាក្សី «គ» មិនត្រូវបានសួរនៅក្នុងការជំនុំជម្រះលើកទី១ទេ ប៉ុន្តែនៅក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ សាក្សី «គ» បានជាសះស្បើយពីជំងឺ និងត្រឡប់មកកម្ពុជាវិញ ក្នុងករណីនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍អនុញ្ញាតចំពោះការដាក់ភស្តុតាងថ្មីនេះ។

| ការជំនុំជម្រះលើកទី១ | ការជំនុំជម្រះលើកទី២ |
| --- | --- |
| មិនបានសាកសួរសាក្សី «គ» | អនុញ្ញាតឱ្យសួរសាក្សី «គ» |

ការដាក់ភស្តុតាងថ្មី ដែលមិនផ្ទុយនឹងបញ្ញត្តិនៃមាត្រា ១០៨ នៃក្រមនីតិវិធីប្បវេណី ត្រូវបានអនុញ្ញាតនៅក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍

(៣) ការជំនុំជម្រះលើកទី២ តុលាការនៃបណ្ដឹងឧទ្ធរណ៍ មិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ ពីព្រោះសកម្មភាពនៃការជំនុំជម្រះលើកទី១ (សកម្មភាពបណ្ដឹងដែលបានធ្វើឡើងនៅក្នុងការជំនុំជម្រះលើកទី១ ដោយរាប់បញ្ចូលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) មានអានុភាពចំពោះការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ ហៅថា «**របបជំនុំជម្រះបន្ត**»។




មាត្រា ២៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ជាគោលការណ៍ តុលាការនៃបណ្ដឹងឧទ្ធរណ៍ មិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ លើកលែងតែការកំណត់ចំណុចវិវាទរបស់តុលាការជាន់ទាប មានលក្ខណៈមិនត្រឹមត្រូវ ហើយមានភាពចាំបាច់ពិសេស ត្រូវកំណត់ចំណុចវិវាទជាថ្មី។

ឧទាហរណ៍ នៅក្នុងការជំនុំជម្រះលើកទី១ ដើមចោទ «ក» អះអាងអំពីសិទ្ធិលើបំណុលចំនួន $10,000 ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ចុងចម្លើយបានអះអាងអំពីការរលត់សិទ្ធិលើបំណុលដោយអាជ្ញាយុកាល ហើយតុលាការ បានកំណត់ចំណុចវិវាទ «តើមានអត្ថិភាពនៃសិទ្ធិលើបំណុលឬទេ?» ការកំណត់ចំណុចវិវាទនេះមិនត្រឹមត្រូវទេ ចំណុចវិវាទដែលត្រឹមត្រូវគឺ « តើសិទ្ធិលើបំណុលនេះត្រូវរលត់ដោយអាជ្ញាយុកាលឬទេ?»

មាត្រា ២៧៣ និងមាត្រា ១១៦ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

សាលាដំបូង

«ក» ដើមចោទ

ទាមទារប្រាក់កម្ចីចំនួន $10,000 ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ

តើមានអត្ថិភាពនៃសិទ្ធិលើបំណុលឬទេ ?

«ខ» ចុងចម្លើយ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

***សេចក្ដីសម្រេចបញ្ជាប់៖***

បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $10,000 មកឱ្យដើមចោទ«ក»

តុលាការនៃបណ្តឹងឧទ្ធរណ៍

«ខ»
ដើមបណ្តឹងឧទ្ធរណ៍

តើមានអត្ថិភាពនៃសិទ្ធិលើបំណុលឬទេ ?

«ក»
ចុងបណ្តឹងឧទ្ធរណ៍

ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

អ្នកដែលទទួលខុសត្រូវក្នុងការបញ្ជាក់អង្គហេតុនេះ

តើសិទ្ធិលើបំណុលនេះ ត្រូវរលត់ដោយអាជ្ញាយុកាលឬទេ ?

# ២.៤ សាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍

តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវចេញសាលដីកាចុងក្រោយចំពោះបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។ ក្នុងករណីបណ្តឹងឧទ្ធរណ៍មិនស្របច្បាប់ដែលមិនអាចកែតម្រូវបាន ដូចជាករណីផុតសិទ្ធិប្តឹងឧទ្ធរណ៍ ឬ អ្នកប្តឹងឧទ្ធរណ៍គ្មានសិទ្ធិប្តឹងឧទ្ធរណ៍ គ្មានផលប្រយោជន៍នៃបណ្តឹងឧទ្ធរណ៍ជាអាទិ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវចេញសាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍ ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ហៅថា **សាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍** ។

មាត្រា ២៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី




## *ខ្លឹមសារនៃសេចក្ដីសម្រេចបញ្ជាប់៖*

① លើកចោលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី10.03.2018 របស់ដើមបណ្ដឹងឧទ្ធរណ៍ «ខ»

② ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមបណ្ដឹងឧទ្ធរណ៍ «ខ»

# ២.៥ សាលដីកាប្រាននចោលបណ្ដឹងឧទ្ធរណ៍

ក្នុងករណី តុលាការយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ ត្រឹមត្រូវ តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវចេញសាលដីកាប្រាននចោលបណ្ដឹងឧទ្ធរណ៍ ទោះបីជាសំអាងហេតុនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវក៏ដោយ បើយល់ឃើញថា សេចក្ដីសម្រេចបញ្ចប់នៃសាលក្រមនៃការជំនុំជម្រះលើកទី១នោះត្រឹមត្រូវ បើផ្អែកលើសំអាងហេតុផ្សេងទៀត ។

ឧទាហរណ៍ «ក» ធ្វើបណ្តឹងបដិសេធបិតុភាពដោយយក «ខ» ជាចុងចម្លើយ តុលាការនៃការជំនុំជម្រះលើកទី១ យល់ឃើញថា

| តុលាការនៃការជំនុំជម្រះលើកទី១ | តុលាការនៃបណ្តឹងឧទ្ធរណ៍ |
|---|---|
| **សំអាងហេតុ**<br>«ខ» កើតក្នុងអំឡុងពេល 300 ថ្ងៃ គិតចាប់ពីថ្ងៃលែងលះ | **សំអាងហេតុ**<br>«ខ» កើតក្រោយអំឡុងពេល 300 ថ្ងៃ គិតចាប់ពីថ្ងៃលែងលះ |
| **សេចក្តីសម្រេចបញ្ចប់**<br>បដិសេធបិតុភាពរវាង «ក» និង «ខ» | ***សេចក្តីសម្រេចបញ្ចប់***<br>បដិសេធបិតុភាពរវាង «ក» និង «ខ» |

# តុលាការនៃបណ្ដឹងឧទ្ធរណ៍យល់ឃើញថា

## *សេចក្ដីសម្រេចបញ្ចប់*

① ច្រានចោលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី 01.03.2018 របស់ដើមបណ្ដឹងឧទ្ធរណ៍ «ខ»

② ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមបណ្ដឹងឧទ្ធរណ៍ «ខ»

# ២.៦ សាលដីកាទទួលស្គាល់បណ្ដឹងឧទ្ធរណ៍

ក្នុងករណីតុលាការនៃបណ្ដឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មានភាពមិនត្រឹមត្រូវ ឬ ខុសនីតិវិធីធ្ងន់ធ្ងរ តុលាការត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ដោយធ្វើការវិនិច្ឆ័យដោយខ្លួនឯងជំនួសសាលាដំបូង ឬបញ្ជូនត្រឡប់ ឬផ្ទេររឿងក្ដី។

សាលក្រមនៃការជំនុំ
ជម្រះលើកទី១
មិនត្រឹមត្រូវឬ ខុសនីតិវិធី
ធ្ងន់ធ្ងរ

វិនិច្ឆ័យដោយខ្លួនឯង
ជំនួសសាលាដំបូង





បញ្ជូនត្រឡប់ទៅតុលាការដើម

ផ្ទេររឿងក្ដីទៅតុលាការដែលមានសមត្ថកិច្ច

## ក. ការលុបចោល និងជំនុំជម្រះដោយខ្លួនឯង

(១) តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើទី១ មានភាពមិនត្រឹមត្រូវ ។

សាលក្រមដែលមានភាពមិនត្រឹមត្រូវ គឺជាសាលក្រមដែលមានកំហុស ឧ. សាលក្រមដើមសម្រេចឱ្យដើមចោទ «ក» ឈ្នះក្តី ដែលខ្លឹមសារថា បង្គាប់ឱ្យ «ខ» លុបចោលនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L ទាំងមូលដោយមូលហេតុរំលាយកិច្ចសន្យាលក់ទិញចុះថ្ងៃទី01.01.2016 ផ្អែកលើអត្ថិភាពនៃអង្គហេតុរំលាយកិច្ចសន្យា ប៉ុន្តែតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា គ្មានអត្ថិភាពនៃអង្គហេតុរំលាយទេ គប្បីឱ្យ «ក» ចាញ់ក្តី បើផ្អែកលើសំអាងហេតុផ្សេង។

# សាលាដំបូង

«ក»
ដើមចោទ

រំលោយកិច្ចសន្យាលក់ទិញ
ចុះថ្ងៃទី01.01.2016 ដោយមូលហេតុ
«ខ» មិនបានអនុវត្តកាតព្វកិច្ចបង់
ប្រាក់តាមកិច្ចសន្យា

«ខ»
ចុងចម្លើយ

បានបង់ប្រាក់ថ្លៃលក់ទិញតាម
ពេលកំណត់នៅក្នុងកិច្ចសន្យា
លក់ទិញចុះថ្ងៃទី01.01.2016

***សេចក្ដីសម្រេចបញ្ចប់៖***

បង្គាប់ឱ្យចុងចម្លើយ «ខ» ធ្វើនីតិវិធីលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L
ទាំងមូល ឱ្យទៅ «ក» ដោយមូលហេតុរំលោយកិច្ចសន្យាលក់ទិញ
ចុះថ្ងៃទី01.01.2016

តុលាការនៃបណ្តឹងឧទ្ធរណ៍

«ខ»
ដើមបណ្តឹងឧទ្ធរណ៍

បានបង់ប្រាក់ថ្លៃលក់ទិញតាមពេលកំណត់នៅក្នុងកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី01.01.2016

«ក»
ចុងបណ្តឹងឧទ្ធរណ៍

រំលាយកិច្ចសន្យាលក់ទិញចុះថ្ងៃទី 01.01.2016 ដោយមូលហេតុ «ខ» មិនបានអនុវត្តកាតព្វកិច្ចបង់ប្រាក់តាមកិច្ចសន្យា

***សេចក្តីសម្រេចបញ្ចប់៖***

លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ០១ "ក" ភ.ព.រ.វ ចុះថ្ងៃទី02.10.2017 របស់សាលាដំបូងរាជធានីភ្នំពេញ

ក្នុងករណីខ្លះ តុលាការនៃបណ្ដឹងឧទ្ធរណ៍ មិនលុបចោលសាលក្រម នៃការជំនុំជម្រះលើកទី១ទាំងស្រុងនោះទេ ប៉ុន្ដែ ធ្វើការផ្លាស់ប្ដូរ ឬ កែប្រែខ្លឹមសារសាលក្រមនៃការជំនុំជម្រះលើកទី១ ។

ឧទាហរណ៍ នៅក្នុងការជំនុំជម្រះលើកទី១ ដើមចោទ «ក» ទាមទារឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $10,000 និង បង់ប្រាក់ក្នុងអត្រា 5%/ឆ្នាំនៃទឹកប្រាក់ $10,000 មកឱ្យដើមចោទ "ក" ។ ចុងចម្លើយបានអះអាងអំពីការសងមួយផ្នែក $4,000 ប៉ុន្ដែតុលាការមិនទទួលស្គាល់ និងចេញសាលក្រមតាមការទាមទាររបស់ដើមចោទ ។

# សាលាដំបូង

«ក» ដើមចោទ

អត្ថិភាពនៃសិទ្ធិលើបំណុល $10,000 & សិទ្ធិលើបំណុល 5%/ឆ្នាំនៃទឹកប្រាក់$10,000

«ខ» ចុងចម្លើយ

សិទ្ធិលើបំណុលត្រូវរលត់មួយផ្នែក (បានសង $4,000)

## *សេចក្ដីសម្រេចបញ្ចប់៖*

① បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $10,000 មកឱ្យចុងចម្លើយ «ក»

② បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ក្នុងអត្រា 5%/ឆ្នាំនៃទឹកប្រាក់ $10,000 មកឱ្យដើមចោទ «ក» គិតចាប់ពីថ្ងៃទី 01.03.2017 រហូតដល់សងរួច

## តុលាការនៃបណ្តឹងឧទ្ធរណ៍

**«ក» ចុងបណ្តឹងឧទ្ធរណ៍**

អត្ថិភាពនៃសិទ្ធិលើបំណុល $10,000 & សិទ្ធិលើបំណុល5%/ឆ្នាំនៃទឹកប្រាក់ $10,000

**«ខ» ដើមបណ្តឹងឧទ្ធរណ៍**

សិទ្ធិលើបំណុលរលត់មួយផ្នែក ( $4,000 )

# *សេចក្តីសម្រេចបញ្ចប់៖*

① លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ០១ "ក" ភ.ព.វ.វ ចុះថ្ងៃទី 02.10.2017 របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី ① និងទី ② មួយផ្នែកដោយសម្រេចជាថ្មីដូចមានកំណត់ក្នុងចំណុចទី ② និងទី ③ នៃសាលដីកានេះ

② បង្គាប់ឱ្យដើមបណ្តឹងឧទ្ធរណ៍ «ខ» បង់ប្រាក់ $6,000 មកឱ្យចុងបណ្តឹងឧទ្ធរណ៍ «ក»

③ បង្គាប់ឱ្យដើមបណ្តឹងឧទ្ធរណ៍ «ខ» បង់ប្រាក់ក្នុងអត្រា 5%/ឆ្នាំនៃទឹកប្រាក់ $6,000 មកឱ្យចុងបណ្តឹងឧទ្ធរណ៍ «ក» គិតចាប់ពីថ្ងៃទី01.03.2017 រហូតដល់ថ្ងៃសងរួច

④ ប្រាក់ប្រដាប់ក្តី 60% ជាបន្ទុករបស់ «ខ» និង 40% ជាបន្ទុករបស់ «ក»

(២) តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ ខុសនីតិវិធីធ្ងន់ធ្ងរ។ កំហុសនីតិវិធីធ្ងន់ធ្ងរ មានដូចជាការសាកសួរសាក្សីនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការប្រកាសសាលក្រមដោយចៅក្រមដែលមិនមែនជាអ្នកវិនិច្ឆ័យជាអាទិ៍។

សាលាដំបូង

01.02.2016

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

រៀបចំការអះអាងចំណុចវិវាទ និងភស្តុតាង

ការសាកសួរសាក្សី

សាក្សី «គ»៖ នៅថ្ងៃទី 01.01.2016 «ខ» បានទៅហាងលក់Computer របស់ «ក» ហើយបានទិញ Computer 06 គ្រឿង តម្លៃ $ 10,000 ខ្ញុំជាបុគ្គលិក ហើយខ្ញុំជាអ្នកសម្របសម្រួលការលក់ទិញរបស់ពួកគាត់

សាលាដំបូង

«ក» ដើមចោទ

សាក្សី «គ» បញ្ជាក់ពីអត្ថិភាពនៃកិច្ចសន្យាលក់ទិញ

«ខ» ចុងចម្លើយ

«ខ» មានកាតព្វកិច្ចត្រូវបង់ប្រាក់ $10,000 តាមកិច្ចសន្យាលក់ទិញចុះថ្ងៃទី01.01.2016

នត្ថិភាពនៃកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី 01.01.2016

***សេចក្ដីសម្រេចបញ្ចប់៖***

បង្គាប់ឱ្យចុងចម្លើយ«ខ» បង់ប្រាក់ $10,000 ឱ្យទៅដើមចោទ «ក»

តុលាការនៃជំនុំជម្រះ
លើបណ្ដឹងឧទ្ធរណ៍

«ខ»
ដើមបណ្ដឹង
ឧទ្ធរណ៍

សាក្សី «គ« បញ្ជាក់
ពីអត្ថិភាពនៃ
កិច្ចសន្យាលក់ទិញ

«ក»
ចុងបណ្ដឹង
ឧទ្ធរណ៍

នត្ថិភាពនៃកិច្ចសន្យា
លក់ទិញ ចុះថ្ងៃទី
01.01.2016

① តុលាការនៃបណ្ដឹងឧទ្ធរណ៍នឹងធ្វើការសាកសួរសាក្សី «គ» ជាថ្មីម្ដងទៀត។ ក្នុងករណីតុលាការនៃបណ្ដឹងឧទ្ធរណ៍មិនជឿលើចម្លើយរបស់សាក្សី «គ» តុលាការនឹងលុបចោលសាលក្រមដើម។

② ក្នុងករណីតុលាការនៃបណ្ដឹងឧទ្ធរណ៍ជឿលើចម្លើយរបស់សាក្សី «គ» តុលាការនឹងច្រានចោលបណ្ដឹងឧទ្ធរណ៍។

③ ក្នុងករណីតុលាការយល់ឃើញថាមានភាពចាំបាច់ក្នុងការកំណត់ចំណុចវិវាទថ្មី តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវចេញដីកាសម្រេចបង្វិលមកនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

មាត្រា ១១៦ កថាខណ្ឌទី ៤ និងមាត្រា ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

## ខ. ការលុបចោល និងបញ្ជូនត្រឡប់

(១) ក្នុងករណី តុលាការនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ បានទទួលពាក្យបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមលើកចោលបណ្តឹងរបស់តុលាការនៃការជំនុំជម្រះលើកទី១ បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវតាមច្បាប់ ហើយមានភាពចាំបាច់ត្រូវទាញហេតុផលបន្ថែមទៀតចំពោះរឿងក្តីនោះ តុលាការនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមនៃការជំនុំម្រះលើកទី១ ដោយបញ្ជូនត្រឡប់ទៅតុលាការដើម ។

តុលាការអាចលើកចោលបណ្តឹង ដោយមូលហេតុខ្វះលក្ខខណ្ឌនៃបណ្តឹង បណ្តឹងផ្ទុយច្បាប់ដែលមិនអាចកែតម្រូវបាន។

សាលាដំបូង

«ក»
ដើមចោទ

បណ្តឹងខុសច្បាប់

«ខ»
ចុងចម្លើយ

សុំឱ្យតុលាការរំលាយកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី01.01.2016

*សេចក្តីសម្រេចបញ្ជាប់៖*

① លើកចោលបណ្តឹងចុះថ្ងៃទី01.01.2016 របស់ដើមចោទ «ក»

② ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ «ក»

តុលាការនៃបណ្ដឹងឧទ្ធរណ៍

«ក» ដើមបណ្ដឹងឧទ្ធរណ៍

«ខ» ចុងបណ្ដឹងឧទ្ធរណ៍

មិនមែនជាបណ្ដឹងដែលខុសច្បាប់ទេ

សុំឱ្យតុលាការរំលាយកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី01.01.2016

*សេចក្ដីសម្រេចបញ្ចប់៖*

① លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ០១ "ក" ភ.ព.រ.រ ចុះថ្ងៃទី02.10.2017 របស់សាលាដំបូងរាជធានីភ្នំពេញ

② បញ្ជូនរឿងក្ដីនេះទៅសាលាដំបូងរាជធានីភ្នំពេញវិញ

(២) ក្នុងករណីតុលាការដើមទទួលស្គាល់ការទាមទារ ប៉ុន្តែមានកំហុសនីតិវិធីធ្ងន់ធ្ងរដោយអវត្តមានភាគី នៅពេលទាញហេតុផលដោយផ្ទាល់មាត់ដោយភាគីមិនបានទទួលការបញ្ជូនដីកាកោះតាមច្បាប់។ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវលុបចោលសាលក្រមដើម និងបញ្ជូនត្រឡប់ ដើម្បីធ្វើនីតិវិធីទាញហេតុផលឡើងវិញ។

**ទាក់ទងនឹងការបញ្ជូន**

ឧទាហរណ៍ ដើមចោទ «ក» បានដាក់ពាក្យបណ្ដឹងប្ដឹង «ខ» ឱ្យបង់ប្រាក់ $10,000 ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី01.01.2016។ តុលាការបានធ្វើនីតិវិធីបណ្ដឹងដោយអវត្តមានចុងចម្លើយ «ខ» និងមិនបានធ្វើការពិនិត្យលើរបាយការណ៍ស្ដីពីការបញ្ជូន រហូតដល់ចប់នីតិវិធី។ «ខ» បានធ្វើបណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ដោយមូលហេតុការជំនុំជម្រះលើកទី១ មានកំហុសនីតិវិធីធ្ងន់ធ្ងរ។

**សាលាដំបូង**

ដីកាកោះ

«ក» ដើមចោទ — មានវត្តមាន

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

«ខ» ចុងចម្លើយ — អវត្តមាន

មិនបានធ្វើការបញ្ជូន

ដីកាកោះ

«ក» ដើមចោទ — មានវត្តមាន

នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

«ខ» ចុងចម្លើយ — អវត្តមាន

***សេចក្ដីសម្រេចបញ្ជាប់៖***

បង្គាប់ឱ្យចុងចម្លើយ «ខ» បង់ប្រាក់ $ 10,000 មកឱ្យដើមចោទ «ក»

ករណីតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលសាលក្រមដើម ហើយបញ្ជូនត្រឡប់ទៅតុលាការដើម តុលាការនៃបណ្តឹងឧទ្ធរណ៍នឹងមិនសម្រេចអំពីប្រាក់ប្រដាប់ក្តីនោះទេ ពីព្រោះការសម្រេចនេះមិនទាន់បានកំណត់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិរបស់ភាគីនៅឡើយ។ ការសម្រេចនេះពាក់ព័ន្ធតែជាមួយនឹងកំហុសនីតិវិធីរបស់តុលាការជាន់ទាបតែប៉ុណ្ណោះ។

ការសម្រេចអំពីប្រាក់ប្រដាប់ក្តី គឺជាការកំណត់អំពីបន្ទុកនៃចំណាយដែលត្រូវបានប្រើប្រាស់នៅក្នុងអំឡុងពេលនីតិវិធីរបស់តុលាការដោយភាគី ហេតុនេះមូលដ្ឋាននៃការសម្រេចគឺផ្អែកទៅលើការកំណត់ជាស្ថាពរនូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត។

## គ. ការលុបចោល និងផ្ទេររឿងក្តី

តុលាការនៃបណ្តឹងឧទ្ធរណ៍ លុបចោលសាលក្រមដើម និងផ្ទេររឿងក្តីទៅតុលាការដែលមានសមត្ថកិច្ច ក្នុងករណី តុលាការនៃការជំនុំជម្រះលើកទី១ បានធ្វើការជំនុំជម្រះលើរឿងក្តីដែលខ្លួនគ្មានសមត្ថកិច្ច។

នៅក្នុងរឿងក្តីទាក់ទងនឹងឋានៈបុគ្គល សមត្ថកិច្ចជម្រះក្តី ជាសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចលើលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គល ឬ លំនៅឋានដែលភាគីនោះទទួលមរណភាព។ ក្នុងករណីលំនៅឋានរបស់ភាគីមិនច្បាស់លាស់ គឺកំណត់យកទីសំណាក់ បើគ្មានទីសំណាក់ គឺកំណត់យកទីតាំងស្នាក់នៅចុងក្រោយ បើមិនអាចកំណត់បានទេ បណ្តឹងឋានៈបុគ្គលស្ថិតក្រោមសមត្ថកិច្ចរបស់សាលាដំបូងរាជធានីភ្នំពេញ។

ឧទាហរណ៍ ដើមចោទ «ក» ប្ដឹងលែងលះជាមួយនឹងចុងចម្លើយ «ខ» ។ «ក» មានលំនៅឋាននៅខេត្តក្រចេះ ហើយ «ខ» មានលំនៅឋាននៅខេត្តកំពង់ចាម ពួកគេបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅខេត្តកំពង់ចាម បន្ទាប់មក អ្នកទាំងពីរបានរស់នៅខេត្តសៀមរាបអស់រយៈពេល៥ឆ្នាំ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយ អ្នកទាំងពីរមានភាពរកាំរកូសនឹងគ្នា «ខ» បានចាកចេញពីសៀមរាបមករស់នៅភ្នំពេញ ។ «ក» បានប្ដឹងលែងលះ «ខ» មកសាលាដំបូងរាជធានីភ្នំពេញ ហើយសាលាដំបូងនេះ ក៏បានចាត់ការលើបណ្ដឹង និងចេញសាលក្រម បន្ទាប់មក «ខ» បានប្ដឹងឧទ្ធរណ៍នឹងសាលក្រមនេះ ។



សាលាដំបូង

«ក» ដើមចោទ

សំណុំរឿងលែងលះ

«ខ» ចុងចម្លើយ

***សេចក្តីសម្រេចបញ្ចប់៖***

① «ក» និង «ខ» លែងលះគ្នា

② បង្គាប់ឱ្យចុងចម្លើយ «ខ»ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L មួយផ្នែកមកឱ្យដើមចោទ «ក» ដោយមូលហេតុបែងចែកទ្រព្យរួម

③ បង្គាប់ឱ្យ ដើមចោទ «ក» បង់ប្រាក់ $50,000 មកឱ្យចុងចម្លើយ «ខ»

ប្រការ ១០,២៧,២៨ នៃប្រកាសអន្តរក្រសួង
ស្តីពីការចុះបញ្ជីសិទ្ធិប្រត្យក្សពាក់ព័ន្ធជាមួយនឹងក្រមរដ្ឋប្បវេណី

## តុលាការនៃជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍

«ខ»
ដើមបណ្ដឹងឧទ្ធរណ៍

«ក»
ចុងបណ្ដឹងឧទ្ធរណ៍

សំណុំរឿងលែងលះ




តុលាការដែលមានសមត្ថកិច្ច

***សេចក្ដីសម្រេចបញ្ជាប់៖***

① លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ០១ "ក" ភ.ព.រ.វ ចុះថ្ងៃទី 02.10.2017 របស់សាលាដំបូងរាជធានីភ្នំពេញ

② ផ្ទេររឿងក្ដីនេះទៅសាលាដំបូងខេត្តសៀមរាប

# សូមអរគុណ!

